# សៀវភៅមគ្គុទ្ទេសក៍
# ស្តីពី



# ដំណើរការស្នើសុំលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក លើថ្នាលបច្ចេកវិទ្យាព័ត៌មានវិទ្យា

Organized by Business Registration Department
Ministry of Commerce, Cambodia

# មាតិកា


ផ្នែកទី១ ព័ត៌មានទូទៅ ៣

១. អ្វីទៅជាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក? ៤

២. កាតព្វកិច្ចតម្រូវដោយច្បាប់សម្រាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ៤

៣. ប្រភេទនៃការស្នើសុំ ៤

៤. នីតិវិធីនៃការស្នើសុំ ៥

៥. ការលើកលែង ៨

៦. តម្លៃសេវាស្នើសុំ ៨

ផ្នែកទី២ ការស្នើសុំលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណតាមប្រព័ន្ធអេឡិចត្រូនិក លើថ្នាលបច្ចេកវិទ្យាព័ត៌មានវិទ្យា ៩

១. ការបង្កើតគណនីលើកម្មវិធីទូរស័ព្ទដៃ CamDigiKey ១១

២. ការ Log In ចូលទំព័រ Portal ១៣

៣. ដំណើរការនៃការស្នើសុំ ១៥

៤. ការទូទាត់ប្រាក់ ១៨

៥. ការពិនិត្យស្ថានភាព និងទទួលបានសារជូនដំណឹងពីកំហុសផ្សេងៗ ១៩

៦. ការទទួលបានលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណ ឌីជីថល ២១

# ផ្នែកទី ១

# ព័ត៌មានទូទៅ




## ហេតុអ្វីត្រូវស្នើសុំលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក?



១. បង្កើតអត្តសញ្ញាណផ្ទាល់ខ្លួនសម្រាប់អាជីវកម្មអ្នក



២. ជៀសវាងការផាកពិន័យផ្សេងៗ និងការតម្រូវឲ្យបញ្ឈប់អាជីវកម្ម



៣. ទទួលបានការគាំពារតាមផ្លូវច្បាប់



៤. ទាក់ទាញអតិថិជន ឬវិនិយោគិនដែលបញ្ជាទិញក្នុងទំហំធំ ឬចង់សហការជាមួយ



៥. ជួយសម្រួលដល់ការទទួលកម្ចីពីធនាគារ និងការវិនិយោគពីវិនិយោគិន



៦. បំពេញកាតព្វកិច្ចជាពលរដ្ឋក្រោមច្បាប់ និងបទបញ្ញត្តិនៃប្រទេសកម្ពុជា

## ១. អ្វីទៅជាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក?




សំដៅទៅដល់សកម្មភាពទិញ លក់ ដូរ ផ្លាស់ប្តូរទំនិញ ឬសេវា ដោយរាប់បញ្ចូលទាំងសកម្មភាពពាណិជ្ជកម្ម និងរដ្ឋប្បវេណី ព្រមទាំងសកម្មភាព និងប្រតិបត្តិការនានារបស់រដ្ឋ តាមប្រព័ន្ធអេឡិចត្រូនិក ដែលបានបង្កើតជាកិច្ចសន្យាទិញលក់។

## ២. កាតព្វកិច្ចតម្រូវដោយច្បាប់សម្រាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក



រាល់រូបវន្តបុគ្គល សហគ្រាសឯកបុគ្គល និងនីតិបុគ្គល ឬសាខាក្រុមហ៊ុនបរទេស ដែលនឹងប្រកបអាជីវកម្ម ឬធ្វើប្រតិបត្តិការ ឬសកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

## ៣. ប្រភេទនៃការស្នើសុំ

| សម្រាប់រូបវន្តបុគ្គល | សម្រាប់សហគ្រាសឯកបុគ្គល | សម្រាប់នីតិបុគ្គល ឬសាខាក្រុមហ៊ុនបរទេស |
|---|---|---|
| • តម្រូវអោយស្នើសុំលិខិតអនុញ្ញាតពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក | • តម្រូវអោយស្នើសុំលិខិតអនុញ្ញាតពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក | • តម្រូវអោយស្នើសុំអាជ្ញាបណ្ណពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក |

# ៤. នីតិវិធីនៃការស្នើសុំ

## ក. លិខិតអនុញ្ញាតសម្រាប់រូបវន្តបុគ្គល




រូបវន្តបុគ្គល ដែលនឹងប្រកបអាជីវកម្ម ធ្វើប្រតិបត្តិការ ឬ សកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាត តាមថ្នាលប្រព័ន្ធស្វ័យប្រវត្តកម្ម ដោយត្រូវបំពេញព័ត៌មាន និងភ្ជាប់ឯកសារតម្រូវដូចខាងក្រោម៖

- ✓ អត្តសញ្ញាណបណ្ណដែលនៅមានសុពលភាពរបស់បុគ្គលស្នើសុំ
- ✓ រូបថត ៤x៦ របស់រូបវន្តបុគ្គល ដែលថតមិនលើសពី៣ខែមុន (ផ្ទៃពណ៌ស)
- ✓ មានគណនីនៅគ្រឹះស្ថានហិរញ្ញវត្ថុណាមួយ (Bank Account)
- ✓ ឯកសារគំរូអាជីវកម្ម (Business Model)
- ✓ ទម្រង់កិច្ចការពារអ្នកប្រើប្រាស់សម្រាប់ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- ✓ វិញ្ញាបនបត្រសេវាអនឡាញ និងឈ្មោះដែនពីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ (ប្រសិនបើមាន)
- ✓ បុគ្គលស្នើសុំត្រូវបំពេញពាក្យស្នើសុំតាមប្រព័ន្ធស្វ័យប្រវត្តកម្ម



- ➢ លិខិតអនុញ្ញាតមានសុពលភាព ០២ (ពីរ) ឆ្នាំ គិតចាប់ពីថ្ងៃផ្តល់លិខិតអនុញ្ញាតដោយក្រសួងពាណិជ្ជកម្ម និងអាចបន្តសុពលភាពបាន
- ➢ រយៈពេលផ្តល់សេវាលិខិតអនុញ្ញាត ចាប់ពី៣ ទៅ៥ថ្ងៃ នៃថ្ងៃធ្វើការ ប្រសិនបើឯកសារស្នើសុំត្រឹមត្រូវ និងគ្រប់គ្រាន់។



## ខ. លិខិតអនុញ្ញាតសម្រាប់សហគ្រាសឯកបុគ្គល




សម្រាប់សហគ្រាសឯកបុគ្គល ដែលនឹងប្រកបអាជីវកម្ម ធ្វើប្រតិបត្តិការ ឬសកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធ អេឡិចត្រូនិក ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាត តាមថ្នាលប្រព័ន្ធស្វ័យប្រវត្តកម្ម ដោយត្រូវបំពេញ ព័ត៌មាន និងភ្ជាប់ឯកសារតម្រូវដូចខាងក្រោម៖

- ✓ វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម
- ✓ កម្មវត្ថុអាជីវកម្មសម្រាប់ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (កម្មវត្ថុលេខ 47910)
- ✓ ប័ណ្ណប៉ាតង់
- ✓ មានគណនីនៅគ្រឹះស្ថានហិរញ្ញវត្ថុណាមួយ (Bank Account)
- ✓ ឯកសារគំរូអាជីវកម្ម (Business Model)
- ✓ ទម្រង់កិច្ចការពារអ្នកប្រើប្រាស់សម្រាប់ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- ✓ វិញ្ញាបនបត្រសេវាអនឡាញ និងឈ្មោះដែនពីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ (ប្រសិនបើមាន)
- ✓ បុគ្គលស្នើសុំត្រូវបំពេញពាក្យស្នើសុំតាមប្រព័ន្ធស្វ័យប្រវត្តកម្ម។



- ➢ លិខិតអនុញ្ញាតមានសុពលភាព ០២ (ពីរ) ឆ្នាំ គិតចាប់ពីថ្ងៃផ្តល់លិខិតអនុញ្ញាតដោយក្រសួងពាណិជ្ជកម្ម និងអាចបន្តសុពលភាពបាន
- ➢ រយៈពេលផ្តល់សេវាលិខិតអនុញ្ញាត ចាប់ពី៣ ទៅ៥ថ្ងៃ នៃថ្ងៃធ្វើការ ប្រសិនបើឯកសារស្នើសុំត្រឹមត្រូវ និងគ្រប់គ្រាន់។



## គ. អាជ្ញាបណ្ណសម្រាប់នីតិបុគ្គល ឬសាខាក្រុមហ៊ុនបរទេស



នីតិបុគ្គល ឬសាខាក្រុមហ៊ុនបរទេសដែលនឹងប្រកបអាជីវកម្ម ធ្វើប្រតិបត្តិការឬសកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណតាមថ្នាលប្រព័ន្ធស្វ័យប្រវត្តកម្ម ដោយត្រូវបំពេញព័ត៌មាន និងភ្ជាប់ឯកសារតម្រូវដូចខាងក្រោម៖

- ✓ វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម
- ✓ កម្មវត្ថុអាជីវកម្មសម្រាប់ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច (កម្មវត្ថុលេខ 47910)
- ✓ ប័ណ្ណប៉ាតង់
- ✓ វិញ្ញាបនបត្រសេវាអនឡាញ និងឈ្មោះដែនពីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- ✓ ឯកសារអំពីមធ្យោបាយទូទាត់ប្រាក់ផ្តល់ដោយបុគ្គលផ្តល់សេវាទូទាត់ដែលទទួលស្គាល់ដោយធនាគារជាតិនៃកម្ពុជា (Bank Account)
- ✓ ឯកសារគំរូអាជីវកម្ម (Business Model)
- ✓ ទម្រង់កិច្ចការពារអ្នកប្រើប្រាស់សម្រាប់ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- ✓ គំរូកិច្ចសន្យារវាងអន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្មអំពីការតម្រូវការព័ត៌មានអប្បបរមា (សម្រាប់អន្តរការី)
- ✓ បុគ្គលស្នើសុំ ត្រូវបំពេញព័ត៌មានស្នើសុំតាមប្រព័ន្ធស្វ័យប្រវត្តកម្ម។



- ➢ អាជ្ញាបណ្ណមានសុពលភាព ០៣ (បី) ឆ្នាំ គិតចាប់ពីថ្ងៃផ្តល់លិខិតអនុញ្ញាតដោយក្រសួងពាណិជ្ជកម្ម និងអាចបន្តសុពលភាពបាន
- ➢ រយៈពេលផ្តល់សេវាអាជ្ញាបណ្ណយ៉ាងយូរ១០ថ្ងៃ នៃថ្ងៃធ្វើការ ប្រសិនបើឯកសារស្នើសុំត្រឹមត្រូវ និងគ្រប់គ្រាន់។





## ៥. ការលើកលែង

ត្រូវបានលើកលែងការតម្រូវឱ្យស្នើសុំលិខិតអនុញ្ញាតប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក ចំពោះរូបវន្តបុគ្គល ឬសហគ្រាសដែលធ្វើសកម្មភាព ឬប្រតិបត្តិការដូចខាងក្រោម៖

- ការផ្សព្វផ្សាយពាណិជ្ជកម្មអំពីទំនិញ ឬសេវារបស់ខ្លួន រួមបញ្ចូលទាំងការផ្សព្វផ្សាយលក់ទំនិញ ឬសេវាដែលមិនមែនជាសំណើបង្កើតកិច្ចសន្យា
- ការបម្រុងទុកសេវាដែលមិនមានការកក់ប្រាក់ ឬទូទាត់តម្លៃ ដោយអតិថិជនឬអ្នកប្រើប្រាស់
- ការលក់ទំនិញ ឬសេវារបស់រូបវន្តបុគ្គល ឬសហគ្រាសឯកបុគ្គល ដែលមានផលរបរនៅក្រោមកម្រិតផលរបរជាអ្នកជាប់ពន្ធតូច
- ការលក់ទំនិញឬសេវាដែលមានលក្ខណៈគ្រួសារ ឬតាមរដូវកាលប្រមូលផល
- ការលក់ទំនិញ ឬស្នាដៃសិល្បៈផ្ទាល់ខ្លួនសុទ្ធសាធ
- ការបង្ហាត់បង្រៀនដោយឯកជនផ្ទាល់ខ្លួន ឬអប់រំអំពីសាសនារបស់រដ្ឋ
- ការបង្ហាត់បង្រៀនដោយសមាគមន៍ដែលមិនរកប្រាក់ចំណេញដោយផ្ទាល់ ឬប្រយោល និងសកម្មភាព ឬប្រតិបត្តិការដោយស្ថាប័នរដ្ឋក្នុងការផ្តល់សេវាសាធារណៈក៏ត្រូវបានលើកលែងការតម្រូវឱ្យស្នើសុំលិខិតអនុញ្ញាតផងដែរ។

## ៦. តម្លៃសេវាស្នើសុំ



ការស្នើសុំលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណតាមប្រព័ន្ធអេឡិចត្រូនិកត្រូវបង់តម្លៃសេវាតាមរយៈប្រព័ន្ធស្វ័យប្រវត្តកម្ម ដោយផ្អែកតាមការកំណត់ក្នុងប្រកាសរួមរបស់អន្តរក្រសួង៖

| លិខិតអនុញ្ញាត រូបវន្តបុគ្គល | លិខិតអនុញ្ញាត សហគ្រាសឯកបុគ្គល | អាជ្ញាបណ្ណ នីតិបុគ្គល ឬសាខាក្រុមហ៊ុនបរទេស |
|---|---|---|
| ២០០ ០០០៛ | ៤០០ ០០០៛ | ១ ០០០ ០០០៛ |

# ផ្នែកទី ២

## ការស្នើសុំលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណពាណិជ្ជកម្ម តាមប្រព័ន្ធអេឡិចត្រូនិកលើ ថ្នាលបច្ចេកវិទ្យាព័ត៌មានវិទ្យា



ដំណើរការនៃការស្នើសុំលិខិតអនុញ្ញាត អាជ្ញាបណ្ណពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក លើថ្នាលបច្ចេកវិទ្យាព័ត៌មានវិទ្យា ត្រូវបានចែកចេញជា ៦ជំហានធំៗ ៖



១. ការបង្កើតគណនីលើកម្មវិធីទូរស័ព្ទដៃ CamDigiKey



២. ការ Log In ចូលទំព័រ Portal



៣. ដំណើរការនៃការស្នើសុំ



៤. ការទូទាត់ប្រាក់



៥. ការពិនិត្យស្ថានភាព និងទទួល
បានសារជូនដំណឹងពីកំហុសផ្សេងៗ



៦. ការទទួលបានលិខិតអនុញ្ញាត
ឬអាជ្ញាបណ្ណ ឌីជីថល







# ទាញយកកម្មវិធីទូរស័ព្ទដៃ CamDigiKey[១]

**ពី App Store ឬ Google Play ដាក់លើទូរស័ព្ទរបស់អ្នក**

App Store | Google Play

១ **CamDigiKey** គឺជាកម្មវិធីសម្រាប់ផ្ទៀងផ្ទាត់អត្តសញ្ញាណតាមរយៈ **QR Code** របស់រាជរដ្ឋាភិបាលកម្ពុជា ដែលភ្ជាប់អ្នកប្រើប្រាស់ទៅសេវាកម្មរដ្ឋាភិបាលឌីជីថលរបស់ប្រទេសកម្ពុជា។





## ១. ការបង្កើតគណនី CamDigiKey App

១.១. ស្វែងរកកន្លែងដែលមានសេវាទូរស័ព្ទ និងប្រព័ន្ធអ៊ិនធឺណេតគ្រប់គ្រាន់។

១.២. ដោនឡូតកម្មវិធី CamDigiKey ជំនាន់ ២.០ ពី App Store ឬ Google Play លើទូរស័ព្ទដៃរបស់អ្នក។

១.៣. ចូលទៅកាន់កម្មវិធីទូរស័ព្ទដៃ CamDigiKey ជំនាន់២.០ រួចចុចប៊ូតុង “ចុះឈ្មោះ” ។

១.៤. បញ្ចូលលេខទូរស័ព្ទដៃ និងអ៊ីម៉េលនៅក្នុងកម្មវិធីទូរស័ព្ទដៃ ហើយបញ្ចូលលេខកូដ OTP ដែលបានផ្ញើទៅកាន់ទូរស័ព្ទ និងអ៊ីម៉េលរបស់លោកអ្នក។

១.៥. បញ្ចូលលេខកូដសម្ងាត់ផ្ទាល់ខ្លួនចំនួន ៦ ខ្ទង់ រួចចុចប៊ូតុង “បន្ទាប់” ។





→



១.៦. ចុច "**ខ្ញុំត្រូវការប្រើប្រាស់ Face ID**" ប្រសិនបើអ្នកត្រូវការ Face ID ។

១.៧. ស្កេនមុខរស់រវើករបស់អ្នក ដោយចុចប៊ូតុង "ចុចឱ្យជាប់ដើម្បីកត់ត្រា" តាមការណែនាំរបស់កម្មវិធី។

១.៨. ស្កេនអត្តសញ្ញាណប័ណ្ណខ្មែរ (សម្រាប់សញ្ជាតិខ្មែរ) និងលិខិតឆ្លងដែន (សម្រាប់សញ្ជាតិបរទេស) ហើយព័ត៌មាននឹងត្រូវបានទាញយកមកដោយស្វ័យប្រវត្តិ រួចចុច "បន្ទាប់"។










១.៩. ផ្ទៀងផ្ទាត់ព័ត៌មានឡើងវិញម្តងទៀត ហើយចុចលើប្រអប់ធានាអះអាងព័ត៌មានដែលបានបញ្ចូល និងឯកសារដែលបានផ្តល់ជូន គឺជាព័ត៌មានពិតប្រាកដ និងត្រឹមត្រូវ រួចចុច "បន្ទាប់"។

១.១០. រង់ចាំការឆ្លើយតបក្នុងរយៈពេល ៨ ម៉ោងនៃម៉ោងធ្វើការ។

១.១១. លោកអ្នកបានបង្កើតគណនី CamDigiKey ជំនាន់ ២.០ ដោយជោគជ័យ។









# ២. ការ Login In ចូលទំព័រ Portal

២.១. ចូលទៅតំណរគេហទំព័រ www.registrationservices.gov.kh លើកុំព្យូទ័ររបស់អ្នក រួចចុចប៊ូតុង “អាជ្ញាបណ្ណជំនាញ” ផ្នែកខាងលើនៃគេហទំព័រ។ ស្វែងរកពាក្យ “ក្រសួងពាណិជ្ជកម្ម” រួចចុចលើពាក្យ “ប្រព័ន្ធស្វ័យប្រវត្តកម្ម ក្នុងការស្នើសុំលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក”




ឬ ចូលតំណរ https://ecommercelicensing.moc.gov.kh លើកុំព្យូទ័ររបស់អ្នក រួចចុចលើប៊ូតុង “ចូលប្រព័ន្ធ”



២.២. ចុច “ទាញយក QR Code” លើកុំព្យូទ័រ ហើយចូលគណនី CamDigiKey App នៅលើទូរស័ព្ទដែលអ្នកបង្កើត រួចចុចប៊ូតុង “ស្កេនកូដ QR”



២.៣. ស្កេន QR Code ដែលអ្នកឃើញជាមួយនឹងកម្មវិធី CamDigiKey App នៅលើទូរស័ព្ទដៃរបស់អ្នក







២.៤. បញ្ចូលលេខកូដផ្ទាល់ខ្លួនចំនួន ៦ខ្ទង់ដែលអ្នកបានបង្កើតពេលបង្កើតគណនី CamDigiKey ទៅក្នុង CamDigiKey App ឬស្កេនក្រយ៉ៅដៃ ឬស្កេនមុខ ប្រសិនបើអ្នកជ្រើសរើសនៅពេលបង្កើតគណនី CamDigiKey។ បន្ទាប់មក អ្នកនឹងចូលទៅកាន់ទំព័រ Portal សម្រាប់ការស្នើសុំលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកលើថ្នាលប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ក្នុងកុំព្យូទ័រដោយស្វ័យប្រវត្តិ។

# ៣. ដំណើរការនៃការស្នើសុំ

៣.១. ចុចលើ "ពាក្យស្នើសុំប្រកបអាជីវកម្ម" ហើយជ្រើសរើសប្រភេទសំណើណាមួយ




៣.២. បំពេញព័ត៌មានពាក្យស្នើសុំឲ្យបានត្រឹមត្រូវ និងពិតប្រាកដច្បាស់លាស់



## ៣.៤. ភ្ជាប់ឯកសារលើបែបបទទម្រង់ពាក្យស្នើសុំ




## ៣.៥. ចុចធីក ( ✓ ) ក្នុងប្រអប់ទាំងពីរ រួចចុច “បន្ទាប់”



## ៣.៦. ពិនិត្យឡើងវិញនូវព័ត៌មាន និងឯកសារដែលបានបំពេញ




## ៣.៧. ចុចប៊ូតុង “ដាក់ស្នើ”



### ៣.៨. សារបញ្ជាក់ពីការដាក់ពាក្យស្នើសុំ




# ៤. ការទូទាត់ប្រាក់

### ៤.១. ជ្រើសរើសមធ្យោបាយទូទាត់ប្រាក់



៤.២. សារបញ្ជាក់ពីការបង់ប្រាក់បានជោគជ័យ




# ៥. ការពិនិត្យស្ថានភាព និងទទួលបានសារជូនដំណឹងពីកំហុសផ្សេងៗ

៥.១. ពេល Log in ចូលទំព័រ Portal នឹងឃើញឯកសារសំណើទាំងអស់



៥.២. ចុចលើឈ្មោះអាជីវកម្មដែលអ្នកចង់តាមដានស្ថានភាពសំណើ អ្នកនឹងឃើញការបញ្ជាក់ស្ថានភាពសំណើលម្អិត




៥.៣. កែតម្រូវព័ត៌មាន និង/ឬ ឯកសារតាមមតិបញ្ជូនត្រលប់ក្នុងស្ថានភាព “មានកំហុស”



# ៦. ការទទួលបានលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណ ឌីជីថល

៦.១. Log in ចូលទំព័រ Portal ចុចលើពាក្យ “សម្រេច” បន្ទាប់មកចុចលើឈ្មោះអាជីវកម្មដែលបានស្នើសុំ




៦.២. នៅពេលអ្នកឃើញស្ថានភាពលម្អិត “ឯកភាព” អាចចុច “ទាញយកគោលការណ៍ និង ទាញយកវិញ្ញាបនបត្រ” ជាទម្រង់ឌីជីថល ដើម្បីធ្វើការបោះពុម្ពដោយខ្លួនឯងបាន





# ជំនួយបន្ថែម


ឡូត៍លេខ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប្រទេសកម្ពុជា

ទូរស័ព្ទ (៨៥៥)-៩៦ ៩៦៣២ ៣៦៣ / ០៨៨ ៦០៨៣ ០៨២ (ភ្ជាប់មកកាន់លេខ៤) សម្រាប់ព័ត៌មានស្នើសុំលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

www.ecommercelicensing.moc.gov.kh


Power by MOC



បោះពុម្ពផ្សាយលើកទី១ ឆ្នាំ២០២៣

រក្សាសិទ្ធិគ្រប់យ៉ាងដោយ នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម អគ្គសេវាពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម

រៀបរៀងដោយ ការិយាល័យអាជ្ញាបណ្ណពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក